ចូល លេខ 2072 ថ្ងៃខែ 10/05/12 ម៉ោង
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ខុទ្ទកាល័យ
ចូល លេខ 1341 ថ្ងៃទី 10.5.012 ម៉ោង 16 បញ្ជូន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០១**

# បទបញ្ជា

## ស្ដីពី

## វិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច

អនុលោមតាមគោលនយោបាយស្ដីពីការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លី ដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល និងយោងតាមស្មារតីប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ជាពិសេសដោយពិនិត្យឃើញតម្រូវការចាំបាច់ និងបន្ទាន់ចំពោះមុខ ក្នុងការធានាសមធម៌ ពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវបទបញ្ជា ឱ្យក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីអនុវត្ត ដូចខាងក្រោម÷

១. ផ្អាកជាបណ្ដោះអាសន្ននូវការផ្ដល់សម្បទានដីសេដ្ឋកិច្ច ។

២. ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ នូវគោលនយោបាយ និងរាល់លក្ខខណ្ឌទាំងឡាយនៃសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលស្ដីពីការផ្ដល់សម្បទានដីសេដ្ឋកិច្ច និងផ្ដោតការយកចិត្តទុកដាក់លើការអនុវត្តកិច្ចសន្យាស្ដីពីសម្បទានដីសេដ្ឋកិច្ច ពិសេសគឺការអនុវត្តតាមគោលនយោបាយរូបមន្តស្បែកខ្លា និងការមិនធ្វើឱ្យប៉ះពាល់ដល់ដីធ្លីសហគមន៍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងគោលដៅធ្វើឱ្យសម្បទានដីសេដ្ឋកិច្ចទាំងនេះ បានផ្ដល់ផលប្រយោជន៍ពិតប្រាកដ ជូនដល់ប្រទេសជាតិ និងប្រជាជន ប្រកបដោយចិរភាព ។

៣. ចំពោះក្រុមហ៊ុនដែលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលរួចហើយ តែមិនបានអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន និងតាមកិច្ចសន្យា ដោយកាប់ឈើលក់ហើយមិនធ្វើការអភិវឌ្ឍដីសម្បទាន, ទន្ទ្រានដីបន្ថែម, ទុកដីចោលទំនេរសម្រាប់លក់បន្ត, ធ្វើអាជីវកម្មខុសលក្ខខណ្ឌនៃកិច្ចសន្យា, បំពានដីរបស់ប្រជាពលរដ្ឋ ឬដីសហគមន៍ រាជរដ្ឋាភិបាលនឹងដកហូតនូវដីសម្បទានសេដ្ឋកិច្ចទាំងនោះមកវិញ ។ ដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានដកហូតមកវិញនោះ នឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ដោយផ្ទាល់ ។

៤. ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានទទួលការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយមុនថ្ងៃចេញបទបញ្ជានេះ ត្រូវបន្តអនុវត្តតាមគោលការណ៍ច្បាប់ និងនីតិវិធីជាធរមាន ។

គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តបទបញ្ជានេះ ឱ្យបានម៉ឺងម៉ាត់បំផុត និងមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី៧ ខែឧសភា ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ